**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ១៣៧ រថ.អធរ.ប្រក

# ប្រកាស
# ស្តីពី
# ការប្រគល់ភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈលើការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ និងការពិន័យអន្តរការណ៍ជាប្រាក់ និងការផ្តល់ប្រាក់ខ្វាន់លើកទឹកចិត្តទៅឱ្យមន្ទីររ៉ែនិងថាមពល រាជធានី-ខេត្ត

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៥៥ រថ.នក.ប្រក. ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល ស្តីពីការប្រគល់សិទ្ធិជូនមន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ក្នុងការពិនិត្យ សម្រេច និងផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ

- បានឃើញប្រកាសរួមលេខ ១៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសរួមលេខ ១៥៥២ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១ .-**

ប្រគល់ភារកិច្ចលើការគ្រប់គ្រង និងការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈលើការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ និងការពិន័យអន្តរការណ៍ជាប្រាក់ ទៅឲ្យមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ដោយអនុវត្តតាមតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល ដូចក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា(ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I. ការផ្តល់សេវាសាធារណៈ | | | | |
| I. ១. អគ្គនាយកដ្ឋានធនធានរ៉ែ (អាជ្ញាបណ្ណធនធានរ៉ែ) | | | | |
| ក. ការផ្តល់អាជ្ញាបណ្ណ | | | | |
| ១ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ១០០ ០០០ រៀល | ១០ថ្ងៃ | |
| ២ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារសម្រាប់ការផ្តល់អាជ្ញាបណ្ណធនធានរ៉ែផ្សេងទៀត(តាមការប្រគល់សិទ្ធិពីក្រសួង) | ៥០០ ០០០ រៀល | ១៥ថ្ងៃ | |
| ៣ | ផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ១០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៤ | អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃទ្រង់ទ្រាយតូច | ១ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |
| ៥ | អាជ្ញាបណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១ ០០០ ០០០ រៀល | ៤៥ថ្ងៃ | ១ឆ្នាំ |

| | | | | |
|---|---|---|---|---|
| ខ. ការចុះបញ្ជីអាជ្ញាបណ្ណ | | | | |
| ១ | អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ៥០ ០០០ រៀល | ៣០ថ្ងៃ | តាមសុពលភាពអាជ្ញាបណ្ណ |
| ២ | អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ១០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាបណ្ណ |
| ៣ | អាជ្ញាបណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ១០០ ០០០ រៀល | ៤៥ថ្ងៃ | តាមសុពលភាពអាជ្ញាបណ្ណ |
| II. ការពិន័យអន្តរការណ៍ជាប្រាក់ | | | | |
| ១ | ករណីដំណើរការដោយអាជ្ញាបណ្ណធនធានរ៉ែ ផុតសុពលភាព | | | |
| | - អាជ្ញាបណ្ណសិប្បកម្ម | ៥០ ០០០ រៀល/ថ្ងៃ | | |
| | - អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ (ទ្រង់ទ្រាយតូច) | ៥០០ ០០០ រៀល/ថ្ងៃ | | |

**ប្រការ២ .-**

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ដោយអនុវត្តតាមតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | ម.រថ | ក.សហវ |
| I. ការផ្តល់សេវាសាធារណៈ | | | | |
| I. ១. អគ្គនាយកដ្ឋានធនធានរ៉ែ (អាជ្ញាបណ្ណធនធានរ៉ែ) | | | | |
| ក. ការផ្តល់អាជ្ញាបណ្ណ | | | | |
| ១ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ២ | សេវាពិនិត្យ រៀបចំ និងដំណើរការឯកសារ សម្រាប់ការផ្តល់អាជ្ញាបណ្ណធនធានរ៉ែផ្សេងទៀត(តាមការប្រគល់សិទ្ធិពីក្រសួង) | ៥០% | ៤៩% | ១% |
| ៣ | ផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ៤ | អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ៥ | អាជ្ញាបណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |

| | | | | |
|---|---|---|---|---|
| ខ. ការចុះបញ្ជីអាជ្ញាបណ្ណ | | | | |
| ១ | អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ | ៥០% | ៤៩% | ១% |
| ២ | អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| ៣ | អាជ្ញាបណ្ណឧស្សាហកម្ម អាជីវកម្មធនធានរ៉ែ ទ្រង់ទ្រាយតូច | ៥០% | ៤៩% | ១% |
| II. ការពិន័យអន្តរការណ៍ជាប្រាក់ | | | | |
| ១ | ករណីដំណើរការដោយអាជ្ញាបណ្ណធនធានរ៉ែ ផុតសុពលភាព | | | |
| | - អាជ្ញាបណ្ណសិប្បកម្ម | ៥០% | ៤៩% | ១% |
| | - អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ (ទ្រង់ទ្រាយតូច) | ៥០% | ៤៩% | ១% |

**ប្រការ៣ ._**

រដ្ឋទេយ្យករចំណូលរបស់មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវចេញលិខិតបញ្ជាបង់ប្រាក់ចំណូលកម្រៃសេវាសាធារណៈធនធានរ៉ែពីការផ្តល់សេវាសាធារណៈ ឬពីការពិន័យអន្តរការណ៍ជាប្រាក់ឱ្យក្រុមហ៊ុន/អាជីវករ ទៅបង់ចំណូលចូលគណនីចំណូលពីកម្រៃសេវាសាធារណៈធនធានរ៉ែ និងការពិន័យអន្តរការណ៍ របស់មន្ទីររ៉ែ និងថាមពល ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់ពីប្រភេទចំណូល។

**ប្រការ៤ ._**

អនុញ្ញាតឱ្យមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានរៀងៗខ្លួន ពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដូចដែលបានកំណត់ក្នុងប្រការ១ និងប្រការ២ ខាងលើ។

**ប្រការ៥ ._**

មន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រការទាំងឡាយដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល និងប្រកាសរួមលេខ ១៤៥២ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០១៥ របស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ ._**

ចំពោះការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈលើការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ និងការពិន័យអន្តរការណ៍ជាប្រាក់ដែលទទួលបាន មុនការចូលជាធរមានរបស់ប្រកាសរួមលេខ ១៤៥២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ត្រូវអនុវត្តតាមនីតិវិធីនៃការបែងចែកចំណូលដោយអនុលោមតាមប្រកាសរួមលេខ១០០៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈ

ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងប្រកាសរួមលេខ១០០៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំពោះការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈលើការផ្តល់អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ និងការពិន័យអន្តរការណ៍ជាប្រាក់ដែលទទួលបាន ក្រោយការចូលជាធរមានរបស់ប្រកាសរួមលេខ១៥៥២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ៧ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គាធិការ ប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានធនធានរ៉ែ ប្រធាននាយកដ្ឋាននីតិកម្ម និងប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

ស៊ុយ_សែម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ